នស/រកត/០៤៩៦/២៥

# ព្រះរាជក្រឹត្យ

យើង

ព្រះបាទសម្តេច ព្រះ នរោត្តម សីហនុ វរ្ម័ន
រាជហរិវង្ស ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម
ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រី២
-បានឃើញព្រះរាជក្រឹត្យ ថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលជាតិកម្ពុជា
-តាមសេចក្តីស្នើរបស់សម្តេចនាយករដ្ឋមន្ត្រី ទាំងពីរ :

## ទ្រង់ត្រាស់សំរេច :

មាត្រា១ : បង្កើតអាជ្ញាធរជាតិមួយសំរាប់ទទួលបន្ទុកដោះស្រាយកិច្ចការព្រំដែន ហៅថា « អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន » ដែលមានសមាសភាពដូចតទៅ :

| | |
|---|---|
| ១.-សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១ | សហប្រធាន |
| ២.-សម្តេច នាយករដ្ឋមន្ត្រីទី២ | សហប្រធាន |
| ៣.-សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤.-រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៥.-ឯកឧត្តម ខៀវ មុន្នី អតីតប្រធានគណៈកម្មាធិការព្រំដែន | ទីប្រឹក្សាប្រចាំអាជ្ញាធរ |
| ៦.-សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧.-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨.-សហរដ្ឋមន្ត្រីក្រសួងការពារជាតិ | សមាជិក |
| ៩.-អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |

decisiondecre111

១០.-ឯកឧត្តម ទ៉ា គីមហុង ទីប្រឹក្សាសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១
និងសម្តេចនាយករដ្ឋមន្ត្រីទី២ ទទួលបន្ទុកការងារព្រំដែន
ឋានៈស្មើរដ្ឋលេខាធិការ សមាជិកអចិន្ត្រៃយ៍
១១.-ឯកឧត្តម ឡុង វិសាលោ ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ សមាជិក
១២.-ប្រធាននាយកដ្ឋានភូមិសាស្ត្រ អគ្គលេខាធិការ

**មាត្រា២ :** អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានភារកិច្ច ៖

- រៀបចំ និងកសាងលិខិតបទដ្ឋានមានលក្ខណៈច្បាប់ស្តីពីការកំណត់ព្រំដែនដីគោកនិងព្រំដែនសមុទ្រ ដើម្បីយកទៅតំកល់នៅទីស្នាក់ការអង្គការសហប្រជាជាតិ ។
- ស្រាវជ្រាវនិងសិក្សាឱ្យបានហ្មត់ចត់បំផុត ក្នុងការជ្រើសរើសយកផែនទីលំនាំណាមួយសំរាប់ធ្វើការកំណត់បន្ទាត់ព្រំដែនដីគោកនិងព្រំដែនសមុទ្រឱ្យបានច្បាស់លាស់ រវាងព្រះរាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសជិតខាង ។
- ធ្វើការចរចា សំរបសំរួល ដោះស្រាយ និងសំរេចលើបញ្ហាព្រំដែនជាមួយបណ្តាប្រទេសជិតខាង លើរាល់កិច្ចការដែលមានទំនាក់ទំនងលើការងារព្រំដែន ក្រោយពីមានការឯកភាពពីគណៈរដ្ឋមន្ត្រី ។
- សហប្រធានមានសិទ្ធិចុះហត្ថលេខាលើសន្ធិសញ្ញាស្តីពីបញ្ហាព្រំដែន ក្នុងនាមអាជ្ញាធរទទួលបន្ទុកកិច្ចការព្រំដែន ។

**មាត្រា៣ :** អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានយន្តការ២ ជាសេនាធិការ :

<u>យន្តការទី១</u> : ជាគណៈកម្មាធិការនីតិកម្មស្តីពីកិច្ចការព្រំដែន (Task Force sur l'étude juridique) ។ សមាសភាពនិងភារកិច្ចនៃគណៈកម្មាធិការនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

<u>យន្តការទី២</u> : ជាគណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែន (Task Force Technique) ។ សមាសភាពនិងភារកិច្ចនៃគណៈកម្មាធិការនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា៤ :** យន្តការទាំងពីរនេះមានលេខាធិការដ្ឋានរួមមួយអចិន្ត្រៃយ៍ នៅនាយកដ្ឋានភូមិសាស្ត្រនៃទីស្តីការគណៈរដ្ឋមន្ត្រី ហៅថា: លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដែលមាន ៖

-ឯកឧត្តម ទ៉ា គីមហុង ជាសមាជិកអចិន្ត្រៃយ៍អាជ្ញាធរទទួលបន្ទុកលេខាធិការដ្ឋាន
-លោក ឡាស់ លាស់ ជាជំនួយការទទួលបន្ទុកលេខាធិការដ្ឋាន
-ប្រធាននាយកដ្ឋានភូមិសាស្ត្រ អគ្គលេខាធិការអាជ្ញាធរ ជាប្រធានលេខាធិការដ្ឋាន
-ប្រធាននាយកដ្ឋានសុរិយោដី អនុប្រធានលេខាធិការដ្ឋាន
-លេខាធិការនៃគណៈកម្មាធិការនីតិកម្ម ស្តីពីកិច្ចការព្រំដែន ជាសមាជិក
-លេខាធិការនៃគណៈកម្មាធិការបច្ចេកទេស ស្តីពីកិច្ចការព្រំដែន ជាសមាជិក
-មន្ត្រីជំនាញការមួយចំនួន តាមសេចក្តីត្រូវការជាក់ស្តែង

លេខាធិការដ្ឋាននេះជាអ្នកសំរបសំរួលកិច្ចការ រវាងគណៈកម្មាធិការនីតិកម្មស្តីពីកិច្ចការព្រំដែននិងគណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែន ហើយជាក្បាលម៉ាស៊ីនដ្ឋាល និងជាហិរញ្ញកិច្ចរបស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដោយប្រើប្រាស់មន្ត្រីរបស់នាយកដ្ឋានភូមិសាស្ត្រ នាយកដ្ឋានសូរិយោដី មន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ និងមន្ត្រីនៃលេខាធិការដ្ឋានរបស់ឧត្តការទាំង២សំរាប់ជំនួយការ ។ លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការ-គណៈរដ្ឋមន្ត្រី ។

លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ទទួលបន្ទុកកសាងផែនការចំណាយរបស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

**មាត្រា៥** : លេខាធិការដ្ឋាន មានភារកិច្ច ៖

- សិក្សាស្រាវជ្រាវនិងស្វែងយល់បន្ថែមលើការងារបច្ចេកទេស ដែលពាក់ព័ន្ធទៅនឹងបញ្ហាព្រំដែន ដើម្បីរៀបចំ និងកសាងដោយផ្ទាល់ឱ្យបានលិខិតបទដ្ឋានមានលក្ខណៈច្បាប់ សំរាប់យកទៅដាក់ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។
- ចុះពិនិត្យនិងធ្វើការវាស់វែងដល់ទីកន្លែងកើតហេតុនានាតាមបណ្តោយព្រំដែន រួចរាយការណ៍ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដើម្បីពិនិត្យ និងសំរេច ។
- ចូលរួមចរចាជាមួយប្រទេសជិតខាង ដើម្បីកំណត់ជ្រើសរើសយកផែនទីសំរាប់ធ្វើជាមូលដ្ឋានក្នុងការដោះស្រាយបញ្ហាបច្ចេកទេសឱ្យបានត្រឹមត្រូវច្បាស់លាស់ ។
- សហការជាមួយអភិបាល ឬអភិបាលរងខេត្ត-ក្រុងដែលនៅជាប់ព្រំដែនជាមួយប្រទេសជិតខាង ក្នុងការសិក្សាស្រាវជ្រាវលើទីតាំងព្រំដែន សីមា ជាក់ស្តែងទៅនឹងបញ្ហាបច្ចេកទេសជំនាញ រួចរាយការណ៍អំពីលទ្ធផល ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។
- ធ្វើរបាយការណ៍តាមតំណាក់កាលនីមួយៗ អំពីសភាពការណ៍នៃការដោះស្រាយនិងការកំណត់ព្រំដែនជាមួយប្រទេសជិតខាង ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន សំរាប់រាយការណ៍ថ្វាយ និងជូនគណៈរដ្ឋមន្ត្រី ។

**មាត្រា៦**: អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានសិទ្ធិប្រើប្រាស់ត្រារបស់គណៈរដ្ឋមន្ត្រី សំរាប់សំរួលការងារ ។

សមាជិកអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់សហប្រធាន ។

**មាត្រា៧**: អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនមានខ្ទង់ថវិកាដោយឡែក សំរាប់ចំណាយដោយផ្ទាល់ក្នុងការងាររបស់ខ្លួន នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា៨: សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ សម្តេចនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជា រដ្ឋមន្ត្រីពាក់ព័ន្ធ រដ្ឋមន្ត្រីនិងអង្គភាពសាមី និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចព្រះរាជក្រឹត្យនេះ ។

មាត្រា៩: ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ចាប់ពីថ្ងៃឡាយព្រះរាជហស្តលេខានេះតទៅ ហើយជំនួសឱ្យព្រះរាជក្រឹត្យលេខ នស/រកត ០២៩៥-១៩ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៥ ដែលត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ០៨ ខែមេសា ឆ្នាំ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

នរោត្តម រណឫទ្ធិ ហ៊ុន សែន